MH 646KM
កែនៅ 02/11/11

# លិខិតថ្លែងសច្ចាអនុញ្ញាតរបស់អ្នកថែទាំ

ការប្រើលិខិតថ្លែងសច្ចានេះបានអនុញ្ញាតដោយក្រសួងច្បាប់គ្រួសារនៃរដ្ឋកាលីហ្វ័រនី ផ្នែកទី១១ ភាគទី១.៥ (California Family Code ចាប់ផ្តើមពីវគ្គទី ៦៥៥០)។ ការថ្លែងសច្ចានេះនឹងមិនប៉ះពាល់ដល់សិទ្ធិរបស់មាតាបិតា ឬអ្នកអាណាព្យាបាលពេញច្បាប់ ក្នុងការថែរក្សា គ្រប់គ្រងទេ។ ការថ្លែងសច្ចានេះមិនមានន័យថា អ្នកថែទាំមានសិទ្ធិពេញច្បាប់លើជនមិនពេញវ័យនោះទេ។ លិខិតថ្លែងសច្ចានេះក៏មិនមានន័យថា ជនមិនពេញវ័យបានក្លាយទៅជាអ្នកពឹងផ្អែកលើការគ្រប់គ្រងសុខភាពទាំងស្រុងដោយស្វ័យប្រវត្តិដែរ។

ជនមិនពេញវ័យដែលមានឈ្មោះនៅខាងក្រោមនេះរស់នៅក្នុងគេហដ្ឋានខ្ញុំ ហើយខ្ញុំមានអាយុ ១៨ ឆ្នាំឡើងទៅ។

1. ឈ្មោះ (ជនមិនពេញវ័យ)៖ ____________________
2. ថ្ងៃខែឆ្នាំ កំណើត៖ ____________________
3. ខ្ញុំឈ្មោះ (មនុស្សពេញវ័យដែលផ្តល់ការអនុញ្ញាត)៖ ____________________
4. អាស័យដ្ឋានខ្ញុំ៖ ____________________

____________________

☐ ខ្ញុំជាជីដូនជីតា មីងមា ឬ ញាតិសន្តាន របស់ជនមិនពេញវ័យ (បើគូសខ្វែង ត្រូវសរសេរឈ្មោះលើបន្ទាត់ខាងលើ)។

(**ញាតិសន្តាន** ក្នុងវគ្គទី៥ ពាក្យនេះចង្អុលទៅលើ ស្វាមីភរិយា មាតាបិតា ឪពុកចុងម្តាយចុង បងប្អូនប្រុសស្រី បងប្អូនចុង-ប្រុសស្រី បងប្អូនមានឪពុកឬម្តាយទីទៃពីគ្នា មីងមា ក្មួយប្រុសស្រី បងប្អូនជីដូនមួយ ឬអ្នកណាដែលគាត់ហៅពាក្យដំបូងថា "ជី" (ដូចជាជីទួត ជីលួត ជីលា ។ល។ និង ។ល។) ឬក៏ជា ភរិយាស្វាមី នៃជនដូចរៀបរាប់ខាងលើ បើទោះជាគាត់នៅពោះម៉ាយ/មេម៉ាយ ដោយសារគាត់បានលែងលះគ្នារួចទៅហើយ ឬក៏សាមី/ភរិយាបាត់បង់ជីវិតក៏ដោយ។

5. គូសខ្វែងលើប្រអប់មួយ ឬទាំង២ ខាងក្រោមនេះ (ឧទាហរណ៍៖ បើមានតែឪពុក ឬតែម្តាយមកជួបពេលចុះហត្ថលេខាពេលនោះ គឺគេបានឱ្យឱវាទទៅតែម្នាក់)៖

☐ ខ្ញុំបានពន្យល់ណែនាំ មាតាបិតា ឬ អ្នកផ្សេងដែលមានសិទ្ធិគ្រប់គ្រងតាមច្បាប់លើជនមិនទាន់ពេញវ័យពីបំណងខ្ញុំ គឺខ្ញុំអនុញ្ញាតឱ្យគាត់អនុម័តលើផ្នែកថែរក្សាសុខារម្មណ៍ ហើយខ្ញុំនឹងមិនប្រឆាំងគាត់ទេ។

☐ ខ្ញុំមិនអាចទាក់ទងទៅនឹង មាតាបិតា ឬ អ្នកផ្សេងដែលមានច្បាប់គ្រប់គ្រងលើជនមិនពេញវ័យនៅពេលនេះបាន ដើម្បីនឹងជម្រាបគាត់ពីចំណង់ដែលខ្ញុំអនុញ្ញាត។

6. ☐ ថ្ងៃខែឆ្នាំ កំណើតខ្ញុំ៖____________________
7. រូបថត អត្តសញ្ញាប័ណ្ណ (California ប័ណ្ណបើកបររថយន្ត ឬ California អត្តសញ្ញាប័ណ្ណសំគាល់ខ្លួន)៖____________________
   (សូមភ្ជាប់អត្តសញ្ញាប័ណ្ណចម្លងមកជាមួយ: សូមអានទំព័រខាងក្រោយ ចំណុចលេខ៤) លេខអត្តសញ្ញាប័ណ្ណ

**បំរាម: សូមកុំចុះហត្ថលេខាលើក្រដាសបំពេញនេះ បើសិនជាឃ្លាខាងលើណាមួយមិនអធិប្បាយពីខ្លួនអ្នកដោយត្រឹមត្រូវ។ មិនដូច្នេះទេ បើអ្នកចុះហត្ថលេខា អ្នកនឹងធ្វើខុសច្បាប់ ហើយអ្នកនឹងត្រូវផ្តន្ទាទោស ដោយត្រូវពិន័យជាប្រាក់ ជាប់ពន្ធនាគារ ឬជាប់ពិន័យទាំងពីរ។**

ខ្ញុំសច្ចានិងប្រកាសនៅក្រោមច្បាប់នៃរដ្ឋកាលីហ្វ័រនីថា អ្វីៗដែលបានបរិយាយខាងលើគឺទៀងត្រង់ ហើយជាការពិត។
*បើសិនជាជនមិនពេញវ័យឈប់រស់នៅជាមួយអ្នក អ្នកត្រូវគោរពតាមច្បាប់ដោយឱ្យព័ត៌មានទៅ សាលារៀន ក្រសួងសុខាភិបាល ឬក៏សេវាកម្មនានា ដែលអ្នកបានធ្វើលិខិតថ្លែងសច្ចាអនុញ្ញាត។*

____________________ ____________________
ហត្ថលេខាអ្នកថែទាំ ថ្ងៃខែឆ្នាំ

☐ សេចក្តីយល់ព្រមនេះបានបកប្រែជាភាសា____________________ សម្រាប់អតិថិជន និង/ឬអ្នកទទួលខុសត្រូវ។
បើសិនជាអតិថិជននិង/ ឬអ្នកទទួលខុសត្រូវចុះហត្ថលេខាលើសេចក្តីយល់ព្រមដែលមានភាសាផ្សេង ត្រូវដាក់ភ្ជាប់សេចក្តីយល់ព្រមភាសាអង់គ្លេសជាមួយគ្នា។

**សូមសឹកក្រដាសបំពេញនេះនៅក្នុងឯកសារព្យាបាល ខ័ណ្ឌទី២ សេចក្តីអនុញ្ញាត និងដំណឹង**

| | |
|---|---|
| ព័ត៌មានសម្ងាត់នេះ ផ្តល់ជូនលោកអ្នកតាមច្បាប់បញ្ញត្តិរដ្ឋ និងសហព័ន្ធ ដោយរួមមាន ប៉ុន្តែមិនកំណត់ចំពោះតែកិច្ចប្រតិបត្តិ ច្បាប់សង្គមកិច្ច និងស៊ីវិល និងបទដ្ឋានភាពសម្ងាត់ HIPAA ដែលចូលជាធរមាន។ យើងហាមផ្តាច់ចំពោះការចម្លងព័ត៌មានចេញពីឯកសារព្យាបាល បើគ្មានការអនុញ្ញាតជាលាយលាក់អក្សរពីអតិថិជន ឬអ្នកទទួលខុសត្រូវលើកលែងតែបានអនុញ្ញាតតាមច្បាប់។ អ្នកត្រូវបំផ្លាញចោលឯកសារចម្លងទាំងនេះ បន្ទាប់ពីគោលបំណងនៃសំណើបានចប់សព្វគ្រប់។ | ឈ្មោះ៖ ☐ លេខខ្លួន៖ ☐<br>មន្ទីរព្យាបាល៖ ☐ សេវាមន្ទីរលេខ៖ ☐<br>ខោនធី Los Angeles – ក្រសួងសុខារម្មណ៍ |


# លិខិតថ្លែងសច្ចាអនុញ្ញាតរបស់អ្នកថែទាំ

MH 646KM
កែនៅ 02/11/11

# លិខិតថ្លែងសច្ចាអនុញ្ញាតរបស់អ្នកថែទាំ

**សូមចាំថា៖**

- លិខិតថ្លែងសច្ចានេះមិនប៉ះពាល់ដល់សិទ្ធិរបស់មាតាបិតា និង/ឬ អ្នកអាណាព្យាបាលពេញច្បាប់នៃជនមិនទាន់វ័យ ក្នុងផ្នែកថែរក្សា គ្រប់គ្រង និងទទួលខុសត្រូវទេ។ បន្ថែមលើសពីនេះទៅទៀត លិខិតនេះមិនផ្តល់អំណាចដល់អ្នកថែទាំឱ្យមានច្បាប់គ្រប់គ្រងលើជនមិនពេញវ័យឡើយ។
- ជនដែលពឹងផ្អែកលើសេចក្តីថ្លែងសច្ចានេះ មិនមានកំណត់តម្រូវឱ្យធ្វើអ្វីៗបន្ថែម ឬក៏ស្នើសុំឱ្យមានការស៊ើបអង្កេតអ្វីដែរ។
- **សេចក្តីថ្លែងសច្ចានេះមានអនុភាពតាមច្បាប់ទម្លាប់បានត្រឹមតែក្នុងមួយឆ្នាំប៉ុណ្ណោះ គឺរាប់ពីថ្ងៃដែលអ្នកទទួលខុសត្រូវចុះហត្ថលេខាមក។**

## ព័ត៌មានសំខាន់

### ទៅចំពោះអ្នកថែទាំ

1. **<u>ញាតិសន្តាន</u>** ក្នុងវគ្គទី៥ ពាក្យនេះចង្អុលទៅលើ ស្វាមីភរិយា មាតាបិតា ឪពុកចុងម្តាយចុង បងប្អូនប្រុសស្រី បងប្អូនចុង-ប្រុសស្រី បងប្អូនមានឪពុកឬម្តាយទីទៃពីគ្នា មីងមា ក្មួយប្រុសស្រី បងប្អូនជីដូនមួយ ឬ អ្នកណាដែលគាត់ហៅពាក្យដំបូងថា "ជី" (ដូចជាជីទួត ជីលួត ជីលា ។ល។ និង ។ល។) ឬក៏ជា ភរិយាស្វាមី នៃជនដូចរៀបរាប់ខាងលើ បើទោះជាគាត់នៅពោះម៉ាយ/មេម៉ាយ ដោយសារគាត់បានលែងលះគ្នារួចទៅហើយ ឬក៏សាម៉ី/ភរិយា បាត់បង់ជីវិត។
2. បើសិនជាអ្នកមិនជាប់ញាតិសន្តាន ឬបច្ចុប្បន្ននេះឥតមានប័ណ្ណជាឪពុកម្តាយចិញ្ចឹម ច្បាប់អាចស្នើសុំឱ្យអ្នកមានប័ណ្ណចិញ្ចឹម មុននឹងអ្នកអាចយកក្មេងមកថែរក្សាបាន។ បើអ្នកមានសំនួរបន្ថែម សូមទាក់ទងទៅនឹងក្រសួងសង្គមកិច្ចនៅក្បែរគេហដ្ឋានអ្នក។
3. បើសិនជាជនមិនពេញវ័យឈប់រស់នៅជាមួយអ្នក អ្នកត្រូវគោរពតាមច្បាប់ដោយឱ្យព័ត៌មានទៅ សាលារៀន ក្រសួងសុខាភិបាល ឬក៏សេវាកម្មនានា ដែលអ្នកបានធ្វើលិខិតថ្លែងសច្ចាអនុញ្ញាត។
4. បើអ្នកអត់មានអត្តសញ្ញាប័ណ្ណដូចដែលបានស្នើសុំក្នុងវគ្គទី៧ ទំព័រខាងក្រោយ សូមផ្តល់យើងនូវប័ណ្ណសំគាល់ផ្សេងទៀតដូចជា លេខសូស្យាល់ ឬក៏លេខមេឌីកាល (Medi-Cal)។

### ទៅចំពោះសាលារៀន

1. ច្បាប់ផ្នែកលេខ៤៨២០៤ នៃក្រសួងអប់រំបញ្ជាក់ថា លិខិតសច្ចានេះចាត់ទុកជាភ័ស្តុតាងសំខាន់ក្នុងការសម្រេចអាស័យដ្ឋានរស់នៅរបស់ជនមិនទាន់ពេញវ័យ ដោយមិនចាំបាច់តម្រូវឱ្យបង្ហាញលិខិតគ្រប់គ្រងពេញច្បាប់ ឬក៏លិខិតច្បាប់គ្រប់គ្រងផ្សេងណាទៀត លុះត្រាណាតែមជ្ឈមណ្ឌលសិក្សា អាចបង្ហាញភ័ស្តុតាងផ្សេងទៀតថាជនមិនទាន់ពេញវ័យឥតរស់នៅជាមួយអ្នកថែទាំ។
2. មជ្ឈមណ្ឌលសិក្សាអាចសុំព័ត៌មានបន្ថែម បើសិនជាគេមានហេតុផលអាចបញ្ជាក់ថាអ្នកថែរក្សាមានអាស័យដ្ឋានផ្សេង ដោយសំអាងទៅលើអាស័យដ្ឋានក្នុងអត្តសញ្ញាប័ណ្ណ ដែលឱ្យមកតាមវគ្គទី៤ខាងលើ។

### ទៅចំពោះអ្នកថែរក្សាសុខភាព និងសេវាកម្មសុខភាពនានា

1. គ្មានជនណាម្នាក់ដែលប្រតិបត្តិដោយស្មោះត្រង់តាមសេចក្តីថ្លែងសច្ចាអនុញ្ញាតនេះ ទទួលទណ្ឌកម្មដោយផ្តល់នូវសេវាកម្មថែរក្សាសុខភាព ឬទន្តភាពដល់ជនមិនទាន់ពេញវ័យ ព្រោះតែមិនបានដឹងថាសេចក្តីថ្លែងសច្ចានេះមានភាពមិនពិត។ អ្នកផ្តល់សេវាកម្មនឹងមិនទទួលទោស ឧក្រិដ្ឋកម្ម ទោសស៊ីវិល ឬក៏ត្រូវគេដាក់ទោសដោយដកហូតអជ្ញាបត្រ័ប្រតិបត្តិ ដោយសារតែពត៏មានមិនពិតក្នុងសេចក្តីថ្លែងសច្ចាអនុញ្ញាតឡើយ។
2. សេចក្តីថ្លែងសច្ចានេះមិនមានន័យថា ជនមិនពេញវ័យនឹងក្លាយជាអ្នកពឹងផ្អែកទាំងស្រុងលើការថែរក្សាសុខភាពដោយស្វ័យប្រវត្តនោះទេ។

# លិខិតថ្លែងសច្ចាអនុញ្ញាតរបស់អ្នកថែទាំ